ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 11 / 2012
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ:

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ចន្ទ ទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២

## សវនាការលើបញ្ហាសុខភាពជនជាប់ចោទ អៀង សារី

## និងសវនាការលើអង្គសេចក្តី- ថ្ងៃទី ១៣០

រៀបចំដោយ: សែ កុលវុឌ្ឍី និង Roger PHILLIPS

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Roger PHILLIPS, លោក ដាវ អានសាន |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក William Smith, លោក សេង ប៊ុនឃាង, លោក Dale LYSAK. |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Jasper PAUW. |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS. |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE. |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក ពេជ្រ អង្គ, លោក វ៉េន ពៅ, លោកស្រី ស៊ិន សុវ៉ន, លោកស្រី ទី ស្រីនណា, លោកស្រី Christine MARTINEAU, លោកស្រី Nushin SAKARATI. |
| សាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ប៉េជុយ ជីបសែ (TCW-507) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ កញ្ញា Sonia MESSAOUDI , លោក មឿន សុវណ្ណ (មេធាវីប្រឹក្សាសាក្សី) |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.២០ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១១.១០ | បញ្ចប់ម៉ោង៖ ១១.៣០ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.១០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ៥ ម៉ោង និង ១០ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ទាក់ទងនឹងការពិភាក្សាដេញដោលលើបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី | មេធាវីការពារក្តី អៀង សារី<br>សហព្រះរាជអាជ្ញា<br>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ០៩.១២<br>១០.០១<br>១០.២៨ | ១០.00<br>១០.២៨<br>១០.៣៤ |
| សេចក្តីសម្រេចលើសំណើសុំឱ្យមានការបញ្ជាក់ពីបញ្ហាសុខភាពរបស់លោក នួន ជា | អង្គជំនុំជម្រះ | ១០.៥៩ | ១១.០៩ |
| ការស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី អៀង សារី | ១១.៣២<br>១១.៣៥ | ១១.៣៤<br>១១.៣៦ |
| ការតាំងសំណួរទៅសាក្សី ប៉េជុយ ជីបសែ | អង្គជំនុំជម្រះ | ១១.៣៧ | ១១.៤៦ |

| | | | |
|---|---|---|---|
| (TCW-507) | សហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ១១.៤៧ ១៥.៣២ | ១៥.៣១ ១៦.១៥ |
| សំណើសុំទាក់ទងនឹងចម្លើយដែលសាក្សី ប៉ៃ ផុយជីបសែ សម្ភាសន៍ជាមួយ លោក ហង់រី លោកា | មេធាវីការពារក្ដី នួន ជា | ១៦.១៥ | ១៦.២១ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ទាក់ទងការពិភាក្សាដេញដោលលើបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី</u>**

មេធាវីការពារក្ដី អៀង សារី បានធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ទាក់ទងនឹងការពិភាក្សាដេញដោលលើបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី។ បន្ទាប់មកសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្ដឹង រដ្ឋប្បវេណី បានធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលលើបញ្ហាសុខភាពរបស់ អៀង សារី ។ អង្គជំនុំជម្រះ បានសួរបញ្ជាក់ទៅមេធាវីការពារក្ដី អៀង សារី។

**<u>សេចក្ដីសម្រេចលើសំណើសុំអំពីបញ្ហាសុខភាពរបស់ ជនជាប់ចោទ នួន ជា</u>**

មេធាវីការពារក្ដី ជនជាប់ចោទ នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យគ្រូពេទ្យពិនិត្យ ជនជាប់ចោទ នួន ជា ថាតើគាត់អាចចូលរួមដំណើរការសវនាការបានដែរឬទេ។ មេធាវីការពារក្ដី បានស្នើសុំសេចក្ដីចម្លងឯកសារពេទ្យដែលបានពិនិត្យលោក នួន ជា។ អង្គជំនុំជម្រះបានទទួលរបាយការណ៍ពេទ្យពីគ្រូពេទ្យដែលបាន ពិនិត្យ នួន ជា។ របាយការណ៍ពេទ្យបញ្ជាក់ថា ស្ថានភាពសុខភាពរបស់ នួន ជា មិនមានលក្ខណៈធ្ងន់ធ្ងរទេ ហេតុដូច្នេះផ្អែកតាមរបាយការណ៍ពេទ្យ អង្គជំនុំជម្រះសម្រេចអនុញ្ញាតិឱ្យ លោក នួន ជា ចូលរួមតាមដានដំណើរ ការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ របាយការណ៍សុខភាពរបស់ នួន ជា នឹងផ្ដល់ឱ្យភាគី និងមេធាវីការពារក្ដី នួន ជាក្នុងអំឡុងពេលសម្រាក។

**<u>សំណើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ</u>**

ជនជាប់ចោទ នួន ជា តាមរយៈមេធាវីការពារក្ដីរបស់គាត់បានស្នើសុំ លះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់

សវនាការសម្រាប់រយៈពេលពេញមួយថ្ងៃដោយសារមូលហេតុសុខភាព។ អង្គជំនុំជម្រះ បានសម្រេចតាមការស្នើសុំ។

ជនជាប់ចោទ អៀង សារី បានលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការក្នុងអំឡុងពេលស្តាប់សក្ខីកម្មរបស់សាក្សី (TCW-507)។

**<u>ការសាកសួរទៅសាក្សី ប៉េជុយ ជីបសែ TCW-507</u>**

អង្គជំនុំជម្រះបានតាំងសំណួរបឋមមួយចំនួនទាក់ទងនឹងប្រវត្តិសាវតាររបស់សាក្សី ព្រមទាំងប្រាប់អំពីសិទ្ធិនិងករណីកិច្ចរបស់សាក្សី បន្ទាប់មកសហព្រះរាជអាជ្ញាបានចាប់ផ្តើមតាំងសំណួរទៅសាក្សី និងបន្តបន្ទាប់ដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**<u>សំណើសុំដាក់ឯកសារចម្លើយដែលសាក្សី ប៉េ ជុយជីបសែ បានផ្តល់ឲ្យលោក ហង់រី លោកា</u>**

មេធាវីការពារក្តី នួន ជា បានស្នើសុំឲ្យអង្គជំនុំជម្រះដកយកចម្លើយដែលសាក្សី ប៉េជុយ ជីបសែ បានផ្តល់ ទៅឲ្យលោក ហង់រី លោកា ក៏ដូចជាការសង្កេត ឬការកត់សម្គាល់នានារបស់លោក លោកា ចេញពីសាក្សី ប៉េជុយ ជីបសែ ដើម្បីកុំឲ្យប៉ះពាល់ដល់ការយល់ឃើញ ការដឹងលឺរបស់សាក្សីនៅពេលនេះ។

អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងពិចារណាសម្រេចពីបញ្ហានេះនៅព្រឹកថ្ងៃទី១៤ វិច្ឆិកា ដោយបង្គាប់ឲ្យមន្ត្រីតុលាការដកឯកសារចេញពីសាក្សីវិញ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in France |
|---|---|---|---|---|---|---|---|
| E3/3964 | D125/127 | 00224050-00224056<br>00225209-00225214<br>00239975-00239981 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉េជុយ ជីបសែ PĒ CHUY Chip Sè<br>Written Record of Interview of PĒ CHUY Chip Sè<br>Procès verbal d'audition de PĒ CHUY Chip Sè | P | 00224051, 00224053, 00224051-00224052 | 00225210-11, 00225212 | 00239976-77 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/3863 | D83-Annex-00012 | 00287233-00287237, 00812853-00812941 00164149-00164207 00779378-00779435 | [Partial T.] របាយការណ៍ស្តីពីខេត្តសៀមរាបៈ ភូមិភាគឧត្តរថ្មី [ព័ត៌មានពាក់ព័ន្ធមាននៅក្នុងបទសម្ភាសន៍របស់ពុធ ពុំ ត្រង់ទំព័រ៣៥-៣៧] Report on Siem Reap Province: New North Zone [The relevant information is in an interview of Puth Pom on pages 35-37] Province de Siemreap : nouvelle région Nord, phumphiek | P | 00812860-65, 00812868 | 00164153-56, 00164159 | 00779381-85, 00779387 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចឱ្យជនជាប់ចោទ នួន ជា និង អៀង សារី ចូលរួមសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួន (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនសាក្សី ប៉ែជុយ ជីបសែ TCW-507 ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់វិញ និងឱ្យនាំគាត់ត្រឡប់មកកាន់បន្ទប់សវនាការវិញនៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ នៅមុនម៉ោង ០៩.០០ ព្រឹក ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ខៀវ សំផន ត្រឡប់មកបន្ទប់សវនាការវិញក្រោយពេលសម្រាកពេលព្រឹក។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និងខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំគាត់មកកាន់បន្ទប់សវនាការនៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ ពុធ ទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុណធន្ឌា Roger PHILLIPS